# ការប្រកួតប្រជែងបង្កើតវត្ថុច្នៃពីសំរាមសម្រាប់
# គម្រោងភ្នំពេញទីក្រុងស្អាតជាមួយប្រទេសជប៉ុន

ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨

ដើម្បីលើកកម្ពស់ទីក្រុងស្អាត និងជម្រុញមិត្តភាពរវាងជប៉ុន និងកម្ពុជា ស្ថានទូតជប៉ុនប្រចាំកម្ពុជា សូមអញ្ជើញសាធារណៈជនទាំងអស់ចូលរួមបង្កើតវត្ថុច្នៃពីសំរាម សម្រាប់គម្រោងភ្នំពេញទីក្រុងស្អាតជាមួយប្រទេសជប៉ុន។ គម្រោងនេះគឺជាយុទ្ធនាការប្រមូលសំរាម ដែលធ្វើឡើងដោយក្រុមជនជាតិជប៉ុន នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

យើងខ្ញុំរង់ចាំទទួលនូវការចូលរួមដ៏ច្រើនកុះករ!

## ❖ ការបង្កើតវត្ថុច្នៃពីសំរាម

ការបង្កើតវត្ថុច្នៃពីសំរាម ដែលបង្ហាញពីគំនិតច្នៃប្រឌិតក្នុងការបង្កើតឡើងវិញ និងការប្រើប្រាស់ឡើងវិញ នូវវត្ថុធាតុដើមផ្សេងៗ ដើម្បីទីក្រុងស្អាតរបស់យើងទាំងអស់គ្នា។

## ❖ លក្ខខណ្ឌនៃការបង្កើតវត្ថុច្នៃពីសំរាម

- វត្ថុធាតុដើមចម្បងត្រូវតែជារបស់ដែលបានប្រើប្រាស់រួច ដែលអាចកែច្នៃ និងប្រើប្រាស់សារជាថ្មីតាមរូបភាពផ្សេងៗ។
- ទំហំរបស់បង្កើតថ្មី មិនត្រូវធំជាង៤០ x ៤០ សង់ទីម៉ែត្រ ប៉ុន្តែកម្ពស់ និងទម្ងន់មិនត្រូវបានកំណត់ឡើយ។
- សូមដាក់ពាក្យដោយភ្ជាប់ជាមួយនឹងរូបថតនៃវត្ថុច្នៃពីសំរាមនោះ។
- មិនមានកម្រិតពីចំនួននៃការដាក់ពាក្យនោះទេ។ ប៉ុន្តែបេក្ខជនត្រូវតែបំពេញពាក្យសុំមួយចំពោះវត្ថុមួយ។

★ រាល់ឯកសារដែលដាក់ពាក្យមក នឹងមិនអាចដកវិញបានទេ។

## ❖ របៀបនៃការដាក់ពាក្យ

ផ្ញើទៅកាន់អ៊ីម៉ែល info.jpn@pp.mofa.go.jp ដោយដាក់ចំណងជើង" ការដាក់ពាក្យប្រកួតបង្កើតវត្ថុច្នៃពីសំរាម"។

- សូមផ្តល់នូវព័ត៌មានដូចខាងក្រោម៖

១. ឈ្មោះ ភេទ អាយុ សញ្ជាតិ មុខរបរ អាស័យដ្ឋាន អ៊ីម៉ែល លេខទូរស័ព្ទ។

(កំណត់ចំណាំ) ព័ត៌មានផ្ទាល់ខ្លួនដូចជាឈ្មោះ និងមុខរបររបស់បេក្ខជនជ័យលាភីនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។

២. ការពន្យល់អត្ថន័យនៃការបង្កើតវត្ថុច្នៃពីសំរាម ត្រូវមានអក្សរប្រមាណ៣ជួរប្រសិនជាភាសាខ្មែរ ប្រសិនជាភាសាអង់គ្លេសត្រូវមានអក្សរ៥០ពាក្យ។

(កំណត់ចំណាំ) អត្តន័យនៃវត្ថុច្នៃពីសំរាមរបស់បេក្ខជនជ័យលាភីនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

ចំពោះរូបភាពវត្ថុច្នៃពីសំរាមត្រូវផ្ញើភ្ជាប់ជាមួយនិងអ៊ីម៉ែល។

(កំណត់ចំណាំ) ប្រសិនបើផ្ញើតាមរយៈអ៊ីម៉ែល ទំហំត្រូវតែតូចជាង ឬស្មើ5MB។

★ ចំពោះវត្ថុច្នៃពីសំរាមដែលបានបង្កើតហើយ បេក្ខជនត្រូវយកមក និងតាំងបង្ហាញនៅក្នុងកម្មវិធីបើក “គម្រោងភ្នំពេញទីក្រុងស្អាតជាមួយប្រទេសជប៉ុន” នៅថ្ងៃអាទិត្យ ទី១៨ ខែវិច្ឆិកាឆ្នាំ២០១៨ ម៉ោង៧:០០នាទីព្រឹក នៅស្តង់របស់ស្ថានទូតជប៉ុន នៅសួនវត្តបទុមវតី។ ស្តង់ស្ថានទូតជប៉ុនចាប់បើកពីម៉ោង៧:០០ ដល់១០:០០ព្រឹក។

★ រាល់វត្ថុដែលដាក់ពាក្យមក នឹងមិនអាចដកវិញបានទេ។

## ❖ លក្ខខណ្ឌនៃការចូលរួមប្រកួត

បេក្ខជនជាជនជាតិខ្មែរអាចចូលរួមបានដោយសេរី ដោយមិនមានកំណត់អំពី អាយុ ភេទ និងមុខរបរ។

## ❖ ថ្ងៃផុតកំណត់ឈប់ទទួលពាក្យ

ថ្ងៃអង្គារ៍ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨

(កំណត់ចំណាំ) វត្ថុច្នៃពីសំរាមដែលធ្វើរួចរាល់ហើយ ត្រូវយកមកដោយផ្ទាល់នៅក្នុងថ្ងៃកម្មវិធី។

## ❖ ការជ្រើសរើស

ជ័យលាភី៣រូប នឹងត្រូវបានជ្រើសរើស និងវាយតម្លៃយ៉ាងល្អិតល្អន់ដោយគណៈកម្មការរៀបចំគម្រោងភ្នំពេញទីក្រុងស្អាតជាមួយប្រទេសជប៉ុន។

## ❖ ការប្រកាសលទ្ធផល

លទ្ធផលនៃការប្រកួត នឹងត្រូវប្រកាស ក្នុងពិធីបើក “គម្រោងភ្នំពេញទីក្រុងស្អាតជាមួយប្រទេសជប៉ុន” នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៩:១៥នាទីព្រឹក នៅសួនវត្តបទុមវតី។

## ❖ សំណួរផ្សេងៗ

សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាតាមរយៈទូរស័ព្ទលេខៈ០២៣ ២១៧ ១៦១ (#១១២២) ឬអ៊ីម៉ែលៈ info.jpn@pp.mofa.go.jp។

## ❖ ពាក្យសុំ

ពាក្យសុំ អាចទាញយកបានតាមរយៈគេហទំព័រស្ថានទូតជប៉ុនប្រចាំកម្ពុជាដែលមានអាសយដ្ឋានៈ

http://www.kh.emb-japan.go.jp/index-e.htm